



ព្រឹត្តិបត្រផ្សព្វផ្សាយកសិកម្ម AGRICULTURAL EXTENSION BULLETIN
ចេញផ្សាយដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
លេខទី ១៩ ត្រីមាសទី២ ឆ្នាំ ២០២០
A Publication by the Department of Extension for Agriculture, Forestry and Fisheries
Website : http://www.khmeragri.info

# បទពិសោធន៍ជោគជ័យលើមុខរបរចិញ្ចឹមកន្ធាយ

## កសិករ ម៉ៃ សំអូន នៅភូមិប្រាសាទ ឃុំសំរោងយារ ស្រុកពួក ខេត្តសៀមរាប







ដោយ៖ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ព្រឹត្តិបត្រព័ត៌មានកសិកម្មនេះ រៀបចំឡើងក្នុងគោលបំណងចងក្រងនូវរាល់បទពិសោធន៍ជោគជ័យលើការងារ និងមុខរបរផ្សេងៗរបស់ប្រជាកសិករ សហគមន៍ ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានា ដើម្បីធ្វើការផ្សព្វផ្សាយបន្តដល់ប្រជាកសិករ សហគមន៍ និងដៃគូពាក់ព័ន្ធផ្សេងទៀតដែលមិនទាន់ទទួលបានជោគជ័យ ដើម្បីជាចំណេះដឹងបន្ថែមសម្រាប់ធ្វើការអភិវឌ្ឍលើមុខរបររបស់ខ្លួនឱ្យទទួលបានភាពជោគជ័យដូចទៅនឹងប្រជាកសិករជោគជ័យខាងលើផងដែរ។

ព្រឹត្តិបត្រព័ត៌មានកសិកម្មនេះដែរ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកយកបទពិសោធន៍ជោគជ័យរបស់កសិករ **ម៉ៃ សំអូន** មានទីនៅភូមិប្រាសាទ ឃុំសំរោងយារ ស្រុកពួក ខេត្តសៀមរាប ជាកសិករដែលកំពុងទទួលបានភាពជោគជ័យលើការងារចិញ្ចឹមកន្ធាយមកបង្ហាញជូនដូចខាងក្រោម៖

### ១- អំពីប្រវត្តិ

កសិករ **ម៉ៃ សំអូន** បច្ចុប្បន្ន កំពុងរស់នៅក្នុងភូមិប្រាសាទ ឃុំសំរោងយារ ស្រុកពួក ខេត្តសៀមរាប បានរៀបរាប់ប្រាប់ថា ទីតាំងស្រះ ដែលគាត់បានចិញ្ចឹមកន្ធាយនេះកាលដើមឡើយជាដីទំនេរ ដោយសារចង់ទាញយកផលប្រយោជន៍ពីដីនេះ គាត់បាននឹកគិតដល់ការចិញ្ចឹមកន្ធាយ ដោយសារកន្ធាយជាប្រភេទសត្វដែលមានតម្លៃខ្ពស់នៅលើទីផ្សារ និងងាយស្រួលក្នុងការចិញ្ចឹម។





*សត្វកន្ធាយកំពុងស៊ីចំណី*

កសិករ **ម៉ៃ សំអូន** បានរៀបរាប់បន្តទៀតថា មុនពេលចាប់ផ្តើមចិញ្ចឹមដំបូង គាត់បានសិក្សាស្វែងយល់ពីកសិករដទៃទៀតដែលគាត់ទទួលបានជោគជ័យលើការចិញ្ចឹម និងដោយមានការបង្ហាត់បង្ហាញពីមន្ត្រីជំនាញផ្នែកជលផល នៃមន្ទីរ



*មន្ត្រីជំនាញចុះណែនាំនិងផ្លាស់ប្តូរបទពិសោធន៍*

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប ធ្វើឱ្យគាត់អាចក្លាយជាកសិករចិញ្ចឹមកន្ធាយជាលក្ខណៈទ្រង់ទ្រាយធំ ដែលស្រះនីមួយៗមានទំហំ២០ x ៣០ម៉ែត្រ និងអាចចិញ្ចឹមកន្ធាយបានរហូតដល់៣០០០ក្បាលក្នុងមួយស្រះ។



សត្វកន្ធាយក្នុងស្រះចិញ្ចឹមកសិករ ម៉ៃ សំអូន

## ២. បច្ចេកទេសចិញ្ចឹម

កសិករ ម៉ៃ សំអូន បានពន្យល់ពីរបៀបដែលត្រូវចិញ្ចឹមកន្ធាយបានជោគជ័យថា មានការងារមួយចំនួនត្រូវយកចិត្តទុកដាក់ក្នុងនោះមានដូចជា៖ការជីកស្រះ យើងអាចជីកជម្រៅ ១-១,៥ ម៉ែត្រ និងទំហំ ១០០ម៉ែត្រការេឡើងទៅ ដោយរក្សាកម្រិតទឹកថ្លាផ្នែកខាងលើប្រមាណ ៣តឹក ត្រូវជ្រើសរើសទីតាំងជីកស្រះនៅជិតផ្ទះ និងស្ងប់ស្ងាត់ដើម្បីងាយស្រួលក្នុងការថែទាំ ផ្គត់ផ្គង់ទឹក និងឱ្យចំណី ។





ទីតាំងស្រះចិញ្ចឹមកន្ធាយ កសិករ ម៉ៃ សំអូន

មាត់ស្រះត្រូវយកស័ង្កសី ឬសំណាញ់មកព័ទ្ធជុំវិញ កម្ពស់១ម៉ែត្រ ដើម្បីកុំឱ្យកន្ធាយវារឡើងចេញពីស្រះ ហើយដើម្បីបានជាម្លប់សម្រាប់ជាជម្រកដល់កន្ធាយ យើងត្រូវដាំដំណាំហូបឈើហូបផ្លែនៅតាមមាត់ស្រះ និងដាំត្រកួន កំប្លោកកញ្ឆែតក្នុងស្រះ ក្រៅពីនេះយើងត្រូវរៀបចំកន្លែងសម្រាប់ដាក់បន្ទះឬស្សី ឬបន្ទះធ្វើពីស៊ីម៉ងរាងទេរបន្តិចដើម្បីឱ្យកន្ធាយឡើងស៊ីចំណី និងហាលថ្ងៃ។



សត្វកន្ធាយកំពុងស៊ីចំណី

កសិករ ម៉ៃ សំអូន បានបន្តប្រាប់ទៀតថា នៅបាតស្រះត្រូវដាក់ភក់កម្រាស់១-២តឹក និងដាក់ទឹកបញ្ចូលជិតពេញស្រះ បន្ទាប់មកបាចកំបោរស ប្រមាណ១គីឡូ ទុកចោលប្រហែល ២អាទិត្យ។ បន្ទាប់មកទៀតយកថ្នាំធ្វើឱ្យទឹកស្អាតចាក់ចូល





ការរៀបចំស្រះមុនដាក់កន្ធាយចិញ្ចឹម

ស្រះឱ្យបាន១អាទិត្យសិន ចាំលែងកូនកន្ធាយចូលស្រះ។ យើងក៏អាចរៀបចំជាស្រះស៊ីម៉ងត៍ ទៅតាមលទ្ធភាពដើម្បីចិញ្ចឹមកន្ធាយបានដែរ។



អាងស៊ីម៉ង់សម្រាប់ចិញ្ចឹមកន្ធាយ

❖ ការជ្រើសរើសពូជ

ពាក់ព័ន្ធជាមួយនឹងការជ្រើសរើសពូជ គាត់បានប្រាប់ថា ត្រូវតែជាពូជដែលមិនមានជំងឺ ឬមានរបួសដាច់រលាត់ ជាពូជដែលមាំមួន មានទម្ងន់ ១០០ក្រាម ប៉ុនៗគ្នា ដាក់ចិញ្ចឹមក្នុងចន្លោះខែកុម្ភៈដល់ខែឧសភាទើបល្អ ដាក់ចិញ្ចឹមមិនឱ្យលើសពី ៤-៥ក្បាល ក្នុង១ម៉ែត្រការេ មុនដាក់កន្ធាយក្នុងស្រះត្រូវយកកូនកន្ធាយលែងក្នុងសំណាញ់ ១អាទិត្យសិន ដើម្បីមើលកូនណាដែលមិនល្អយកវាចេញ ។



កូនពូជកន្ធាយត្រៀមដាក់ចិញ្ចឹម

❖ ការឱ្យចំណី

កសិករ ម៉ៃ សំអួន បានប្រាប់ថា ការប្រលែងកូនដំបូងត្រូវស្ងោរដំឡូងផ្លាផុយល្អមកិនឱ្យបែកតូចៗយកទៅចាក់លើក្តាមាត់ស្រះឱ្យវាស៊ី បន្ទាប់ពី១ខែក្រោយ យើងអាចចិញ្ច្រាំដំឡូងឆៅល្អិតៗដាក់ឱ្យវាស៊ីបាន។ មិនត្រូវផ្លាស់ប្តូរកន្លែងដាក់ចំណីរបស់វាទេ ដើម្បីឱ្យវាចាំកន្លែងមកស៊ីចំណី ត្រូវបំបែកចំណីទៅតាមទំហំមាត់កន្ធាយ បន្ទាប់ពី៣ខែក្រោយ យើងអាចដាក់ចំណីដូចជា សត្វល្អិតរស់ក្នុងទឹក កំពិស ត្រី ជន្លេន លាសក្តាម និងកង្កែប ឬផ្លែឈើគ្រាប់រុក្ខជាតិផ្សេងៗ និងចិញ្ចឹមត្រីតូចៗក្នុងស្រះជាដើម។



កូនត្រី និងកំពិស សម្រាប់ឱ្យកូនកន្ធាយស៊ី

ចំពោះចំណីច្នៃមានដូចជា កន្ទក់ សណ្តែកសៀងកិនម្សៅត្រីដែលមិនប្រឡាក់ប្រេ បរិមាណចំណីឱ្យវាស៊ីប្រមាណ ៥-៨% នៃទម្ងន់ខ្លួនកន្ធាយឱ្យវាស៊ី២-៣ដងក្នុង១ថ្ងៃ និងមិនត្រូវដាក់លើស ឬខ្វះ



ការធ្វើចំណីផ្សំឱ្យកន្ធាយស៊ី

គាត់បានបន្តប្រាប់ទៀតថា សម្រាប់រដូវវស្សាយើងអាចបើកមាត់ស្រះសងខាងរួចយកសំណាញ់ដាក់ទប់កុំឱ្យកន្ធាយចេញរួច វិធីនេះអាចឱ្យត្រី និងសត្វផ្សេងៗនៅក្នុងទឹកចូលមកក្នុងស្រះដើម្បីជាចំណីសម្រាប់កន្ធាយ ដែលអាចបាន

រយៈពេល២ឬ៣ខែដែរ។

❁ ការថែទាំ

ចំពោះការថែទាំនេះដែរ កសិករ ម៉ៃ សំអួន បានបញ្ជាក់ប្រាប់ថា មិនត្រូវដាក់ចំណីដូចជាត្រីស្អុយឱ្យវាស៊ីនោះទេ ព្រោះអាចបណ្ដាលកន្ធាយកើតជំងឺពោះវៀន ត្រូវផ្លាស់ប្ដូរទឹកដោយបូមទឹកចាស់ចេញ ២០% រួចបូមទឹកល្អចូលវិញ ត្រូវធ្វើការផ្លាស់ប្ដូរ យោងទៅតាមស្ថានភាពទឹកនៅពេលឃើញថាកខ្វក់ជៀសវាងកុំឱ្យវាកើតជំងឺអុច ស។



កន្ធាយកើតជំងឺអុចស

គាត់បានប្រាប់ទៀតថា នៅពេលដែលវាមានជំងឺ ត្រូវចាប់វាមកខ្វេះលាងសម្អាតកន្លែងដែលមានជំងឺចេញ និងដាក់ថ្នាំទុក ២០នាទី ទើបដាក់ចូលស្រះវិញ រាល់៤ខែម្ដង ត្រូវបូមទឹកចេញ រួចចាប់កន្ធាយមកពិនិត្យជំងឺ និងលាងសម្អាតវា និងត្រូវដាក់ថ្នាំសម្អាតទឹក មិនត្រូវឱ្យមានការរំខានពីសត្វផ្សេងៗ ឬមនុស្សឡើយ កន្ធាយជាសត្វត្រូវការភាពស្ងប់ស្ងាត់



កន្ធាយឈានទម្ងន់អាចប្រមូលផលបាន

## ៣. ការប្រមូលផល

កសិករ ម៉ៃ សំអួន បានរៀបរាប់ប្រាប់ថា បន្ទាប់ពីបានចិញ្ចឹមអស់រយៈពេល១២ខែ យើងអាចចាប់វាលក់បាន ព្រោះពេលនោះវាមានទម្ងន់ពី៨ខាំ ទៅ១,២ គីឡូក្រាម ដែលអាចបានតម្លៃប្រមាណ ១០-១២ដុល្លារ ក្នុងមួយគីឡូ។



កន្ធាយឈានទម្ងន់ពី៨ខាំ-១.២គីឡូក្រាម

## ៤. ការវិភាគសេដ្ឋកិច្ច

ពាក់ព័ន្ធនឹងការវិភាគសេដ្ឋកិច្ចគាត់ប្រាប់ថា បច្ចុប្បន្នគាត់មានស្រះចិញ្ចឹមកន្ធាយចំនួន ៤ ដែលស្រះនីមួយៗមានទំហំ២០ x ៣០ម៉ែត្រ និងអាចចិញ្ចឹមកន្ធាយបាន៣០០០ក្បាលក្នុង១ស្រះ។ បើគាត់លក់កន្ធាយចំនួន៥០០០ក្បាល ហើយក្នុង១ក្បាលតម្លៃ ១១ ដុល្លារ គាត់ទទួលបានប្រាក់ចំណេញចំនួន ២០០០០ដុល្លារ បើគិតជាមធ្យម។



កសិករ ម៉ៃ សំអួន រីករាយនិងជោគជ័យលើមុខរបរចិញ្ចឹមកន្ធាយ

**សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមក៖**

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប
- កសិករ ម៉ៃ សំអួន មានទីលំនៅភូមិប្រាសាទ ឃុំសំរោងយារ ស្រុកពួក ខេត្តសៀមរាប

ទំនាក់ទំនងទូរស័ព្ទលេខ៖ ០១១ ២១ ៨៩ ៨៩